ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៤

លេខៈ ៩

ឆ្នាំ២០១៦

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៤

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា អនុវត្តដោយជោគជ័យគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេចបាននូវគោលដៅធំៗជាអាទិ៍ បន្តរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ ការពាររឹងមាំនូវអធិបតេយ្យ និងបូរណភាពទឹកដី សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ពង្រឹងអភិបាលកិច្ច កែទម្រង់ស៊ីជម្រៅ បង្កើនវិនិយោគលើវិស័យអប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយទឹកជំនន់ឆ្នាំ២០១៣ អភិវឌ្ឍន៍ដោយឆាប់រហ័សលើគ្រប់វិស័យ លើកកំពស់ឥតឈប់ឈរនូវជីវភាពរបស់ប្រជាពលរដ្ឋ។

សមិទ្ធផលនេះ បញ្ជាក់ឱ្យឃើញតាមរយៈការធ្វើឱ្យសម្រេចនូវកំណើនសេដ្ឋកិច្ចកើនឡើងដល់ **៧,១%** លើសពីការព្យាករណ៍ដែលបានរំពឹងទុក៧% ដោយបានដាក់ចេញ និងអនុវត្តគោលនយោបាយ និងវិធានការប្រកបដោយប្រសិទ្ធភាព ហ្មត់ចត់ ទន់ភ្លន់ និងទាន់ពេលវេលា ជាពិសេសឈរលើទស្សនៈនៃការដឹកនាំគ្រប់គ្រងសភាពការណ៍តាមបែបចល័ត ដែលធ្វើឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវការអភិវឌ្ឍលើវិស័យសំខាន់ៗ និងកំណើនសេដ្ឋកិច្ចខ្ពស់ជាងការគ្រោងទុកនៅក្នុងច្បាប់ថវិកាដើមឆ្នាំ២០១៤។ ជាលទ្ធផល ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី **១ ០៤៣ ដុល្លារអាមេរិក** នៅឆ្នាំ២០១៣ ដល់ **១ ១៣៨ ដុល្លារអាមេរិក** នៅឆ្នាំ២០១៤។ ទន្ទឹមនេះ អតិផរណាជាមធ្យមប្រចាំឆ្នាំរក្សាបាន៣,៩% ដែលតាមការគ្រោងទុក គឺក្នុងរង្វង់៣,៥% និងអត្រាប្តូរប្រាក់ជាមធ្យមរក្សាបាន៤ ០៣៩រៀល ក្នុងមួយដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៤ ដែលតាមការគ្រោងទុកគឺក្នុងរង្វង់ ៤ ០៥០រៀល។

ជាសក្ខីភាពនាំមកនូវចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៤ កើនឡើង **២៤,៤%** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ ចំណូលសារពើពន្ធកើនឡើង **២៨,១%** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ ចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៤ កើនឡើង **១២,៧ %** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ និងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៤ កើនឡើង **១៨,៥ %** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣។ រីឯចំណាយថវិកាថ្នាក់ជាតិសរុបអនុវត្តបានកើនឡើង ៧,៥% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ ចំណាយថវិការាជធានី ខេត្ត អនុវត្តបានកើនឡើង ១៩,៧ % ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ និងចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានកើនឡើង ១៨,២ % ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានការសន្សំ**អតិរេកថវិកាថ្នាក់ជាតិចំនួន ១ ២០៣ ០៨៨,៨លានរៀល**។ ទាំងនេះបានមកដោយសារ

ការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអនុវត្តច្បាប់ហិរញ្ញវត្ថុយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយរបស់ខ្លួន។

ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានរក្សាយ៉ាងខ្ជាប់ខ្ជួននូវវិន័យថវិកា ដោយត្បិតត្បៀតចំណាយចរន្ត ដើម្បីរក្សាអតិរេកចរន្តសម្រាប់ការវិនិយោគទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងផ្នែកទន់ ចំណាយលើការវិនិយោគ និងចំណាយលើកិច្ចការពារអធិបតេយ្យភាព ដែលជាមូលដ្ឋានសម្រាប់ពង្រឹងកិច្ចការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ ព្រមទាំងពង្រីកសកម្មភាពសេដ្ឋកិច្ច ដើម្បីបង្កើនចំណូល និងលើកកម្ពស់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

ជាមួយនឹងសមិទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤នេះ បានបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្ត និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ឯករាជ្យភាព ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងជំរុញសកម្មភាពសេដ្ឋកិច្ច កសាងហេដ្ឋារចនាសម្ព័ន្ធ បង្កើនកាលានុវត្តភាពការងារ និងអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ជីវភាព ក៏ដូចជាកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ដើម្បីក្លាយជាប្រទេសដែលមានការអភិវឌ្ឍជឿនលឿនតាមផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។ គឺពិតជាសក្តិសម និងត្រឹមត្រូវណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រសិទ្ធនាមថវិកាឆ្នាំ២០១៤ ថា " **ជាថវិកានៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូររបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយគុណភាព និងចីរភាព ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលកំណើនសេដ្ឋកិច្ចភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងការគិតគូរដល់ការអភិវឌ្ឍន៍រយៈពេលវែង ក្នុងបរិការណ៍សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ ការអភិវឌ្ឍន៍នៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ឱ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា** "។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះ លើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារ

ក្នុងការិយបរិច្ឆេទ២០១៤ របស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ដោយការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រ២០១២-២០១៦ របស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច គោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់(GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត (SNAO) ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា សកម្មភាពទាំងនេះនឹងនៅតែបន្តយ៉ាងសកម្ម ដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា


**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៣

**១.១.លក្ខណៈទូទៅ** ........ ៣

**១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម** ........ ៤

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ** ........ ៤

**២. ការគ្រប់គ្រងថវិកា** ........ ៤

**២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា** ........ ៤

**២.២.កិច្ចប្រតិបត្តិការថវិកា** ........ ៥

**៣. លទ្ធផលសវនកម្ម** ........ ៦

**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ៦

៣.១.១. ការដោះស្រាយបណ្តឹងតវ៉ា ........ ៧

៣.១.២. ភាពយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូល ........ ៧

៣.១.៣. ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មក្រុមហ៊ុន សហគ្រាសមួយចំនួន ........ ៨

៣.១.៤. ការយកតួលេខសមតុល្យសល់ក្នុងឆ្នាំ២០១៣ មកបង្វែរចូលថវិកាឆ្នាំ២០១៤ ........ ៨

៣.១.៥. កង្វះវិធានការចំពោះគ្រឹះស្ថានសិក្សាឯកជនដែលមិនបង់ប្រាក់កក់តម្កល់ធានាអប្បបរមា និងមិនមានអាជ្ញាប័ណ្ណ ........ ៩

៣.១.៦. ការមិនបានបង់ចំណូលចូលក្នុងថវិកាជាតិទាន់ពេលវេលា ........ ១០

៣.១.៧. ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់មិនសមស្រប ........ ១១

៣.១.៨.ការប្រើប្រាស់ថវិកាខុសមាតិកាថវិកា ........ ១២

៣.១.៩.ការចំណាយថវិការដ្ឋទេយ្យបុរេប្រទានដោយគ្មានការអនុញ្ញាតពីអាណាប័ក ១៣

៣.១.១០.ការមិនបានបែងចែកភារកិច្ចរវាងអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ........ ១៣

៣.១.១១. កង្វះខាតការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម ........ ១៤

៣.១.១២.ការពុំទាន់បានកត់ត្រាចំណូលផ្សេងៗ ........ ១៥

៣.១.១៣.ការអនុវត្តកិច្ចលទ្ធកម្មពុំមានក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ........ ១៥

៣.១.១៤.ភាពយឺតយ៉ាវក្នុងការផ្ទួផ្គងតួលេខចំណូល ចំណាយថវិកា ........ ១៦

**៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** ........ ១៧

៣.២.១. ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ........ ១៧

៣.២.២. ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់ .. ១៨
៣.២.៣. ការមិនបានកត់ត្រាទ្រព្យសម្បត្តិរដ្ឋចូលក្នុងបញ្ជីសារពើភណ្ឌ..................... ១៩
៣.២.៤.ការប្រមូលចំណូលពីការអនុញ្ញាតរដ្ឋបាលនៅមានកម្រិត .......................... ១៩
**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តន៍អនុសាសន៍សវនកម្ម**............................ ២០
**៥.សេចក្តីសន្និដ្ឋាន** ........................................................................................................ ២៧

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៤

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧ នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានរួមចំណែកយ៉ាងសំខាន់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួនប្រកបដោយជោគជ័យ ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេចបាននូវគោលដៅធំៗ ក្នុងការបន្តពង្រឹងសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកដោយដោយចីរភាព និងបរិយាប័ន្ន ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងអភិបាលកិច្ច និងការកែទម្រង់ស្ថាប័នជាតិសំខាន់ៗ។ សមិទ្ធផលសម្រេចបានក្នុងការអនុវត្តថវិកាឆ្នាំ២០១៤ បានគូសបញ្ជាក់ច្បាស់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការរក្សានូវសុខសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការលើកកម្ពស់គុណភាពសេវាសាធារណៈ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការជំរុញពិពិធកម្មសេដ្ឋកិច្ច ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍស្ថាប័ន ការបង្កើតកាលានុវត្តភាពការងារ និងការអភិវឌ្ឍវិស័យឯកជន រួមទាំងការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញផងដែរ សំដៅបន្តកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាជនកម្ពុជា និងជំរុញការអភិវឌ្ឍន៍ឱ្យមានការរីកចម្រើនឆាប់រហ័សប្រកបដោយចីរភាព និងបរិយាប័ន្ន។

សម្រាប់ការិយបរិច្ឆេទ២០១៤ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគសរុបចំនួន៤៣ អង្គភាព ដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ការអនុវត្តចំណូលថវិកាថ្នាក់ជាតិសម្រេចបានចំនួន **១៥ ២៧០ ៩៤០,៨**លានរៀល ស្មើនឹង**២២,៥៤%** នៃផ.ស.ស គឺបានកើនខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **១១,៧%** ហើយបានកើនឡើង **១៤,៣%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣។

ទាំងនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល តាមរយៈការកែលម្អគោលនយោបាយសារពើពន្ធ ការបង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធ និងអភិបាលកិច្ចល្អក្នុងការប្រមូលចំណូលតាមផ្នែកនីមួយៗ ដូចជា ចំណូលគយ និងរដ្ឋាករ ចំណូលពន្ធដារ និងចំណូលមិនមែនសារពើពន្ធ។ ក្នុងនោះចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អ គឺសម្រេចបាន **៨,០១ % នៃផ.ស.ស** ធៀបនឹងការគ្រោងទុក **៦,៧៥ % នៃផ.ស.ស** តាមរយៈការដាក់ចេញនូវគោលនយោបាយ និងវិធាននៃការប្រមូលចំណូលគយ និងរដ្ឋាករ ហើយចំណូលពន្ធដារក៏ទទួលបានលទ្ធផលល្អប្រសើរ គឺសម្រេចបាន **៥,៤២ % នៃផ.ស.ស** ធៀបនឹងការគ្រោងទុក **៥,០០ % នៃផ.ស.ស** ដោយមានការកែលម្អគោលនយោបាយសារពើពន្ធ និងពង្រឹងរដ្ឋបាលសារពើពន្ធ ក្នុងគោលដៅបង្កើនចំណូលពន្ធ និងកាត់បន្ថយអំពើគេចវេះពន្ធ រីឯចំណូលមិនមែនសារពើពន្ធសម្រេចបានលទ្ធផលល្អប្រសើរដែរ គឺសម្រេចបាន **២,២០ % នៃផ.ស.ស** ធៀបនឹងការគ្រោងទុក **២,០៥ % នៃផ.ស.ស**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា ទោះបីជាការប្រមូលចំណូលសម្រេចបានលទ្ធផលល្អ ក៏នៅមានការងារមួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត មានជាអាទ៍ៈ ការដោះស្រាយបណ្តឹងតវ៉ា ភាពយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូល ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មក្រុមហ៊ុន សហគ្រាសមួយចំនួន ការមិនបានបង់ចំណូលចូលក្នុងថវិកាជាតិទាន់ពេលវេលា ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ការបំពេញកាតព្វកិច្ចសារពើពន្ធ របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ និងការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច។

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិសម្រេចបានចំនួន **១៤ ០៦៧ ៩៣២,០** លានរៀល ស្មើនឹង **២០,៧៧%** នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៣,៥%** ហើយបានកើនឡើង **៧,៥%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣។ ការអនុវត្តចំណាយសម្រេចបានលទ្ធផលគួរកត់សម្គាល់ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក និងឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ចំពោះមុខដែលបានកើតឡើង ជាពិសេស រាជរដ្ឋាភិបាលបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការបានល្អប្រសើរ ការអនុវត្តការបើកផ្តល់តាមប្រព័ន្ធធនាគារបានទៀងទាត់ ទាន់ពេលវេលាដែលនេះជាជោគជ័យដ៏ធំធេង។ ការសន្សំសាច់ប្រាក់បានចំនួន១ ២០៣ ០០៨,៨ លានរៀល ដែលស្ថានភាពដូចនេះ មិនធ្លាប់មានឡើយជាច្រើនឆ្នាំកន្លងមកនេះ។ មិនត្រឹមតែធ្វើឱ្យមានការសន្សំជាសាច់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យក្រសួង ស្ថាប័នមួយចំនួនកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបាន **ទំនិញ សេវា និងសំណង់** ក្នុងបរិមាណច្រើនជាងមុន និងមានគុណភាពល្អជាងមុន ព្រមទាំងកាន់តែចំទិសដៅដែលបានកំណត់។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្តចំណាយថវិកានេះក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន។ ទោះបីលទ្ធកម្ម

សាធារណៈអនុវត្តបានល្អប្រសើរ ប៉ុន្តែគួរធ្វើឱ្យប្រសើរថែមទៀតនូវការកត់សម្គាល់មួយចំនួនដូចជាៈ ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់មិនសមស្រប ការប្រើប្រាស់ថវិកាខុសមាតិកាថវិកា កង្វះខាតការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម ការបំបែកគម្រោង (កញ្ចប់) ដេញថ្លៃ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះសម្រេចបានចំនួន៤ ២៤០ ៤៧៩,៩ លានរៀល ស្មើនឹង**១២២,៦%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៣ ៤៦០ ០០០,០**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **៧៨០.៤៧៩,៩** លានរៀល។

**ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

ការអនុវត្តចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តសម្រេចបានចំនួន **៨១១ ៦៥៩,១** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ចំនួន**២៣,៦%** និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តសម្រេចបាន**៧១៦ ៩០៣,១**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ចំនួន**៩,២%**។ រីឯការអនុវត្តចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រេចបាន **៨៩ ៧១១,៧** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ចំនួន **២,២%** និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រេចបាន **៨៥ ២៨៥,៧**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ចំនួន **២,៩%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជាៈ ការប្រមូលពន្ធអចលនទ្រព្យ ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់

ការមិនបានកត់ត្រាទ្រព្យសម្បត្តិរដ្ឋចូលក្នុងបញ្ជីសារពើភណ្ឌ។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គឺរហូតមកដល់បច្ចុប្បន្ន ទោះបីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្លាប់បានចេញប្រកាស និងសារាចរណែនាំគ្រើនរំលឹកជាញឹកញាប់យ៉ាងណាក៏ដោយក៏ក្រសួង-ស្ថាប័ន និងសាលារាជធានី-ខេត្តមួយចំនួននៅតែមានភាពយឺតយ៉ាវ និងខកខានក្នុងការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យគណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័នភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជនសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងធ្វើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១៤ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង-ស្ថាប័នរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០១៤ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៤៣ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៤នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

– ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

– ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ជំពូកទី ៤ និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

– ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣

– ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

– ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

– អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

– អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៤ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល-ចំណាយតាមរយៈរតនាគារជាតិ និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១៣ | ២០១៤ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| **I. សរុបចំណូល** | **១៣ ៣៦០ ៥៣៤,០** | **១៣ ៦៦៥ ៦២៧,០** | **១៥ ២៧០ ៩៤០,៨** | **១១១,៧%** |
| -ចំណូលចរន្ត | ៨ ៧០៥ ៦០៥,៧ | ៩ ៧១២ ៦២៧,០ | ១០ ៨២៩ ៦៩៦,៦ | ១១១.៥% |
| -ចំណូលមូលធនក្នុងប្រទេស | ៦៨ ១៦៩,៧ | ២៣៣ ០០០,០ | ១៨៣ ៩៩៦,១ | ៧៩,០% |
| -មូលនិធិទ្រទ្រង់ថវិកា | ២៨០ ៦៧៤,៧ | ២៦០ ០០០,០ | ១៦ ៧៦៨,២ | ៦,៤% |
| -ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៣០៦ ០៨៣,៩ | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% |
| **II. សរុបចំណាយ** | **១៣ ០៩០ ៣៨៣,៣** | **១៣ ៥៩៥ ៦២៧,០** | **១៤ ០៦៧ ៩៣២,០** | **១០៣,៥%** |
| -ចំណាយចរន្ត | ៧ ២៨២ ២៥១,០ | ៨ ២៦៨ ៧០៣,០ | ៨ ២០៤ ៤៩១,៧ | ៩៩,២% |
| -ចំណាយមូលធន | ១ ៥០២ ០៤៨,៤ | ១ ៨៦៦ ៩២៤,០ | ១ ៦២៣ ០១០,៤ | ៨៦,៩ |
| -ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៣០៦ ០៨៣,៩ | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% |

### ខ-កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ

#### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១៣ | ២០១៤ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| **I. សរុបចំណូល** | **៧២០ ៣៥៦,៦** | **៦៥៦ ៤៩០,០៥** | **៨១១ ៦៥៩,១៥** | **១២៣,៦%** |
| -ចំណូលចរន្ត | ៥២៥ ០៩៩,០ | ៥៧០ ៥៦៨,០០ | ៦២៦ ៣២៨,១០ | ១០៩,៨% |
| •ចំណូលសារពើពន្ធ | ៥០១ ១៩៦,៩ | ៥៤៣ ៨៦០,០០ | ៥៩៣ ០១៥,០៨ | ១០៩,០% |
| •ចំណូលមិនមែនសារពើពន្ធ | ២៣ ៩០២,១ | ២៦ ៧០៨,០០ | ៣៣ ៣១៣,០២ | ១២៤,៧% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១៩៥ ២៥៧,៦ | ៨៥ ៩២២,០៥ | ១៨៥ ៣៣១,០៥ | ២១៥,៧% |
| **II. សរុបចំណាយ** | **៥៩៩ ០៥៧,៦** | **៦៥៦ ៤៩០,០៥** | **៧១៦ ៩០៣,០៨** | **១០៩,២%** |
| -ចំណាយចរន្ត | ៤៥៦ ៩៩៨,៧ | ៥២០ ៣៩៧,០០ | ៥៨៣ ០៨៩,៤៣ | ១១២,០% |
| -ចំណាយមូលធន | ១២៨ ៧៩១,៣ | ១២០ ៤៩១,០០ | ១១៨ ១៦១,៦០ | ៩៨,១% |
| -ចំណាយសង្កាត់ចំណុះរាជធានី | ១៣ ២៦៧,៦ | ១៥ ៦៥២,០៥ | ១៥ ៦៥២,០៥ | ១០០,០% |

#### ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១៣ | ២០១៤ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | | *2* | *3* | *4 = (3/2)* |
| **I. សរុបចំណូល** | **៧៥ ៦៩២,៨** | **៨៧ ៨០៣,៤៤** | **៨៩ ៧១១,៧៣** | **១០២,២%** |
| -ចំណូលចរន្ត | ១ ៤៤២,៣ | ១ ២៥៤,២៨ | ៣ ៧២៣,៩៩ | ២៩៦,៩% |
| •ចំណូលមិនមែនសារពើពន្ធ | ១ ៤៤២,៣ | ១ ២៥៤,២៨ | ៣ ៧២៣,៩៩ | ២៩៦,៩% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៧៤ ២៥០,៥ | ៨៦ ៥៤៩,១៦ | ៨៥ ៩៨៧,៧៤ | ៩៩,៤% |
| **II. សរុបចំណាយ** | **៧២ ១៧០,៣** | **៨៧ ៨០៣,៤៤** | **៨៥ ២៨៥,៧៣** | **៩៧,១%** |
| -ចំណាយចរន្ត | ៥៦ ៣៥៦,៣ | ៦៩ ០៤៤,២៨ | ៦៦ ៥២៦,៦៥ | ៩៦,៤% |
| -ចំណាយសង្កាត់ចំណុះក្រុង | ១៥ ៨១៤,០ | ១៨ ៧៥៩,១៦ | ១៨ ៧៥៩,០៨ | ១០០,០% |

## ៣.លទ្ធផលសវនកម្ម

### ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

យោងតាមលទ្ធផលនៃការចុះធ្វើសវនកម្ម បានបង្ហាញឱ្យឃើញថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានភាពល្អប្រសើរ សម្រេចបានលើសពីការគ្រោងទុកក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ បញ្ហាមួយចំនួនដែលគួរធ្វើឱ្យប្រសើរឡើងថែមទៀត ដូចបានបង្ហាញដូចខាងក្រោម៖

### ៣.១.១.ការដោះស្រាយបណ្តឹងតវ៉ា

ប្រកាសលេខ៩២៩ សហវ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់មាត្រា ៦ បានចែងថា "ការិយាល័យវិវាទមានតួនាទី និងភារកិច្ចរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងនីតិវិធីដោះស្រាយការតវ៉ា កសាងផែនការប្រចាំឆ្នាំស្តីពីការដោះស្រាយការតវ៉ា"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៤ ការិយាល័យវិវាទនៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធដារមានការយឺតយ៉ាវក្នុងការដោះស្រាយបណ្តឹងតវ៉ា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារអនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសលេខ៩២៩ សហវ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ខាងលើ ជាពិសេស ត្រូវចាត់វិធានការដោះស្រាយបណ្តឹងតវ៉ាឱ្យបានទាន់ពេលវេលា ដើម្បីបង្កើនចំណូលពន្ធ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល (Revenue Mobilization Strategy) រយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ របស់អគ្គនាយកដ្ឋានពន្ធដារក៏បានបញ្ចូលនូវចំណុចនេះផងដែរ ដើម្បីជំរុញឱ្យការប្រមូលបំណុលពន្ធ និងដោះស្រាយបណ្តឹងតវ៉ាមានប្រសិទ្ធភាព។

### ៣.១.២. ភាពយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូល

អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រង់មាត្រា១០៦ បានចែងថា " ចំណូលត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំដែលក្នុងអំឡុងនោះ ចំណូលទាំងនេះត្រូវបានប្រមូលដោយគណនេយ្យករសាធារណៈ "។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ អង្គភាពពន្ធមួយចំនួនមានការយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូលចូលថវិកាឱ្យបានទាន់ពេលវេលាដែលមានចំនួន ១២៧ ៣៦០លានរៀល។

ការអនុវត្តបែបនេះអាចនាំឲ្យចំណូលថវិកាពុំទាន់សមស្របតាមភាពជាក់ស្តែង និងមិនឆ្លុះបញ្ចាំងតាមឆ្នាំថវិកា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំដល់អង្គភាពប្រតិបត្តិធ្វើការជម្រះផ្ទេរ និងបង់ចំណូលដែលប្រមូលបានចូលថវិការដ្ឋឱ្យបានទាន់ពេលវេលាតាមឆ្នាំថវិកា ដើម្បីឱ្យស្របតាមខ្លឹមសារនៃលិខិតបទដ្ឋានខាងលើ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែសូមបញ្ជាក់ថា អគ្គនាយកដ្ឋានពន្ធដារមានបញ្ហាប្រឈមក្នុងការផ្ទេរចំណូលមួយចំនួន ជាពិសេសលើប្រភេទពន្ធដែលត្រូវបានបិទបញ្ចប់នៅថ្ងៃទី៣១ខែធ្នូ (ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ) និងអាណត្តិលទ្ធកម្មសាធារណៈ រីឯចំពោះប្រភេទពន្ធធម្មតាមិនមានការយឺតយ៉ាវនោះទេ។

### ៣.១.៣.ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មក្រុមហ៊ុន សហគ្រាសមួយចំនួន

ប្រកាសលេខ១៦៥ សហវ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ មាត្រា១ ត្រង់ចំណុច ឆ បានចែងថា " ពិនិត្យឡើងវិញនូវរាល់កម្មវិធីសវនកម្ម ការងារសវនកម្ម លទ្ធផលសវនកម្ម ដើម្បីធានាគុណភាព និងភាពត្រឹមត្រូវនៃការកំណត់ពន្ធឡើងវិញ ស្របតាមគោលនយោបាយសវនកម្ម និងវាយតម្លៃលទ្ធផលការងាររបស់សវនករ"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៤ នាយកដ្ឋានសវនកម្មសហគ្រាសបានដាក់កម្មវិធីសវនកម្មលើសហគ្រាសចំនួន ១ ៩៧៨ ប៉ុន្តែបានអនុវត្តការងារសវនកម្មទទួលបានលទ្ធផលចំនួនតែ៩៨២ សហគ្រាសប៉ុណ្ណោះ គិតជាសមាមាត្រស្មើនឹង៤៩.៦៥% នៃកម្មវិធីសវនកម្មប្រចាំឆ្នាំ (មិនរួមបញ្ចូលលទ្ធផលសវនកម្មនៃកម្មវិធីសវនកម្មឆ្នាំមុនៗទេ)។

ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសហគ្រាស អាចបណ្តាលឲ្យមានបំណុលកកស្ទះដោយសហគ្រាសបាត់ខ្លួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរជំរុញអគ្គនាយកដ្ឋានពន្ធដារអនុវត្តការងារសវនកម្មឱ្យបានសមស្របតាមកម្មវិធីសវនកម្ម ដើម្បីធានាប្រសិទ្ធភាព។

ជាការឆ្លើយតប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែការយឺតយ៉ាវគឺបណ្តាលមកពីការផ្តល់ឯកសាររបស់សហគ្រាសមួយចំនួនដែលត្រូវធ្វើសវនកម្ម មានការយឺតយ៉ាវ ជាពិសេសអ្នកគ្រប់គ្រងដែលមានសិទ្ធិក្នុងការសម្រេចរាល់កិច្ចការរបស់សហគ្រាស ស្ថិតនៅក្រៅប្រទេស (ជនបរទេស) មានការលំបាកក្នុងការទំនាក់ទំនង និងការសហការនៅមានកម្រិត កត្តាទាំងនេះហើយធ្វើឱ្យសវនករខ្វះប្រភពឯកសារក្នុងការផ្តុំព័ត៌មាន ដើម្បីកំណត់ពន្ធឡើងវិញ ដែលធ្វើឱ្យការធ្វើសវនកម្មមានការអូសបន្លាយពេលវេលា។

### ៣.១.៤.ការយកតួលេខសមតុល្យសល់ក្នុងឆ្នាំ២០១៣ មកបង្វែរចូលថវិកាឆ្នាំ២០១៤

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបិទបញ្ជីចំណូលចំណាយសម្រាប់ការិយបរិច្ឆេទ២០១៤ ដោយបានបញ្ជាក់ថា ឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ និងចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូល បង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ជាកំហិត។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៤ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានយកតួលេខសល់ពីឆ្នាំ២០១៣ មានចំនួន ៤៤ ៤៦៧ លានរៀល លើគណនីលេខ ៧០២៧ (អាករលើតម្លៃបន្ថែមកសិកម្មទំនិញនិងសម្ភារៈកសិកម្ម) និងគណនីលេខ ៧១០៧ (ពន្ធគយសម្រាប់ផលិតវត្ថុធាតុដើមឱសថ) មកបង្វែរចូលថវិកាឆ្នាំ២០១៤។

ការយកតួលេខចំណូលនៅសល់មកបញ្ចូលថវិកាឆ្នាំ២០១៤នេះ នាំឱ្យចំណូល ចំណាយថវិកាពុំស្របតាមភាពជាក់ស្តែង និងមិនបានឆ្លុះបញ្ចាំងតាមឆ្នាំថវិកា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យធ្វើការជម្រះផ្ទេរតួលេខដែលប្រមូលបានចូលថវិការដ្ឋឱ្យបានទាន់ពេលវេលាតាមឆ្នាំថវិកា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា តួលេខចំណូលអាករលើតម្លៃបន្ថែមទំនិញនិងសម្ភារៈកសិកម្ម និងពន្ធនាំចូលលើវត្ថុធាតុដើម សម្រាប់ផលិតឱសថចំនួន ៩៤ ៤៦៧ លានរៀល ជាតួលេខសល់ពីចុងឆ្នាំ២០១៣។ ចំណូលប្រភេទនេះ រដ្ឋជាអ្នកទទួលបន្ទុកក្នុងការទូទាត់ជំនួសតាមរយៈអាណត្តិបើកប្រាក់ (ចំណូលព្រម-ចំណាយព្រម) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០១៣ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបន្តបន្ទាប់ដើម្បីសុំការទូទាត់។ ប៉ុន្តែដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំមានឥណទានគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ទើបតួលេខនេះនៅសល់ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញអាណត្តិបើកប្រាក់សម្រាប់ធ្វើការទូទាត់នៅខែកុម្ភៈ ឆ្នាំ២០១៤ ដែលត្រូវបានអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាធ្វើសលាកប័ត្របង្វែរតួលេខនេះចូលថវិការដ្ឋនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤។

### ៣.១.៥. កង្វះវិធានការចំពោះគ្រឹះស្ថានសិក្សាឯកជនដែលមិនបង់ប្រាក់កក់តម្កល់ធានាអប្បបរមា និងមិនមានអាជ្ញាប័ណ្ណ

ដើម្បីពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជនឱ្យមានគុណភាព និងប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ២៩៥ អយក.ហវ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីសំណើសុំអនុញ្ញាតគោលការណ៍ស្តីពីការតម្កល់ប្រាក់កក់អប្បបរមានៅរតនាគារជាតិក្នុងពេលអនុវត្តកិច្ចសន្យាសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជននៅក្រសួងអប់រំ យុវជន និងកីឡា ដោយតម្រូវឱ្យអតិថិជនរូបវន្តបុគ្គល ឬនីតិបុគ្គលចាំបាច់ត្រូវតម្កល់ប្រាក់កក់អប្បបរមានៅរតនាគារជាតិក្នុងពេលអនុវត្តកិច្ចសន្យា សម្រាប់ផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជន និងលិខិតលេខ១៣៨៨ សហវ.អ ទច ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីករណីដាក់ប្រាក់តម្កល់ធានាអប្បបរមានៅអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់ផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៤ មានគ្រឹះស្ថានសិក្សាឯកជនចំនួន៧៤ ដែលបានស្នើសុំអាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជនចំណេះទូទៅ ក្នុងនោះមានគ្រឹះស្ថានសិក្សាឯកជនចំណេះទូទៅចំនួន៥៥ ដែលត្រូវបានក្រសួងប្រកាសទទួលស្គាល់ និងមានគ្រឹះស្ថានសិក្សាឯកជនចំណេះទូទៅចំនួន១៩ទៀត ដែលមិនត្រូវបានក្រសួងប្រកាសទទួលស្គាល់។ ជាមួយគ្នានោះ មានគ្រឹះស្ថានសិក្សាឯកជនចំណេះទូទៅចំនួន១០ប៉ុណ្ណោះ ដែលបានបង់ប្រាក់កក់តម្កល់ធានាអប្បបរមានៅរតនាគារជាតិ និងមានអាជ្ញាប័ណ្ណទទួលស្គាល់ពីក្រសួង ចំណែកឯគ្រឹះស្ថានសិក្សាឯកជនចំនួន៦៤ទៀតមិនទាន់

បានបង់ប្រាក់កក់តម្កល់អប្បបរមានៅរតនាគារជាតិ និងមិនទាន់បានទទួលអាជ្ញាប័ណ្ណទទួលស្គាល់ពីក្រសួង។ ក្រសួងក៏ពុំទាន់មានវិធានការចំពោះគ្រឹះស្ថានសិក្សាឯកជនចំណោះទូទៅដែលមិនទាន់បានបង់ប្រាក់កក់តម្កល់ធានាអប្បបរមានៅរតនាគារជាតិ និងមិនទាន់បានទទួលអាជ្ញាប័ណ្ណពីក្រសួង និងគ្រឹះស្ថានសិក្សាឯកជនចំណោះទូទៅដែលមិនទាន់បានទទួលស្គាល់ពីក្រសួង ហើយគ្រឹះស្ថានទាំងនោះនៅតែធ្វើការបើកបង្រៀន និងរៀននៅឡើយ។

ដោយហេតុនេះក្រសួងអប់រំ យុវជន និងកីឡា គួរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះគ្រឹះស្ថានសិក្សាឯកជនដែលមិនទាន់បង់ប្រាក់កក់តម្កល់ធានាអប្បបរមា និងមិនទាន់មានអាជ្ញាប័ណ្ណពីក្រសួងឱ្យធ្វើការបង់ប្រាក់កក់តម្កល់ធានាអប្បបមា នៅរតនាគារជាតិបានត្រឹមត្រូវតាមការណែនាំ ដើម្បីធានាការគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជនឱ្យមានប្រសិទ្ធភាព និងស្របតាមកម្មវិធីសិក្សារបស់រដ្ឋ។

ឆ្លើយតបចំពោះការលើកឡើងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានបំភ្លឺថា ការងារច្រកចេញចូលតែមួយ ជាជំហានដំបូងដែលដាក់ឱ្យអនុវត្តជាផ្លូវការកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ ចំពោះគ្រឹះស្ថានសិក្សាឯកជនដែលមិនបានបង់ប្រាក់តម្កល់ អប្បបរមាតាមគោលការណ៍កំណត់ ក្រសួងមិនប្រគល់អាជ្ញាប័ណ្ណជូនដែរ។ ក្រោយពីមើលឃើញនូវភាពយឺតយ៉ាវនេះ ក្រសួងក៏បាននិងកំពុងរៀបចំវិធានការមួយចំនួនក្នុងការអនុវត្តបទបញ្ញត្តិ និងលិខិតបទដ្ឋានក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម:

- សេចក្តីជូនដំណឹងស្តីពីការធ្វើសុពលភាពឡើងវិញ ក្នុងការស្នើសុំអាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជន។
- សេចក្តីណែនាំស្តីពីការដាក់ប្រាក់តម្កល់អប្បបរមារបស់គ្រឹះស្ថានសិក្សាឯកជន។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៣.១.៦.ការមិនបានបង់ចំណូលចូលក្នុងថវិកាជាតិទាន់ពេលវេលា**

ដើម្បីប្រមូលចំណូលចូលថវិការដ្ឋឱ្យទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាស លេខ១៣៩៥សហវ.ប្រក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបិទបញ្ជីចំណូលចំណាយ និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិ ក្នុងគោលបំណងជំរុញឱ្យក្រសួងដែលមានសមត្ថកិច្ចក្នុងការប្រមូលចំណូល និងរួសរាន់បង់ចំណូលចូលថវិកាជាតិ ដែលខ្លួនប្រមូលបានយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ជាកំហិត”។

តាមការធ្វើសវនកម្មលើប្រតិបត្តិការប្រមូលចំណូលអនុគណនី៧៣២៨ នៅខែធ្នូ ឆ្នាំ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសុខាភិបាលបានប្រមូលចំណូលចំនួន៤០៣ ៨៣៧ ៨០០រៀល ប៉ុន្តែក្រសួងសុខាភិបាលបានបង់ចំណូលដែលប្រមូលបានខាងលើចូលថវិការដ្ឋចំនួន៣៧១ ៦០៤ ៥០០រៀល។

ការបង់ចំណូលចូលថវិការដ្ឋយឺតយ៉ាវនឹងធ្វើឱ្យការកត់ត្រាតួលេខចំណូលមិនបានពេញលេញ។ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងសុខាភិបាលបង់ចំណូលទាំងអស់ចូលថវិកាជាតិឱ្យបានទាន់ពេលវេលា។

ឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងសុខាភិបាលបានបំភ្លឺថា កន្លងមករជ្ជទេយ្យករចំណូលពុំមែនជាអ្នកប្រមូលចំណូលដោយខ្លួនឯងទេ គឺបណ្តាអង្គភាពជាអ្នកប្រមូល និងយកទៅបង់ចូលថវិការដ្ឋដោយខ្លួនឯង។ ចំណុចនេះ ក្រសួងសុខាភិបាលនឹងបង្កើតភ្នាក់ងារចំណូលតាមអង្គភាពបន្ថែមទៀតយោងតាមប្រកាសរួម និងសារាចរណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.១.៧.ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់មិនសមស្រប

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានគោលការណ៍ណែនាំស្តីពីការបែងចែកតាមប្រភេទ និងការចុះបញ្ជីរបស់អ្នកទទួលការទៅតាមសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុព្រមទាំងតាមកំណត់ត្រាប្រវត្តិការងារ និងបានបែងចែកសមត្ថភាពនៃការដេញថ្លៃទៅតាមតម្លៃនៃកិច្ចសន្យា ដែលមានដូចជា៖ ទី១ ប្រភេទអ្នកទទួលការតូច តម្លៃកិច្ចសន្យាមិនលើសពី ១២៥លានរៀល ទី២ ប្រភេទអ្នកទទួលការមធ្យម តម្លៃកិច្ចសន្យាលើសពី ១២៥លានរៀល ដល់ ៥០០លានរៀល និងទី៣ ប្រភេទអ្នកទទួលការធំ តម្លៃកិច្ចសន្យាលើសពី៥០០លានរៀល។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈមានភារកិច្ច ក្នុងការពិនិត្យវាយតម្លៃលើសំណើសុំតម្លើងប្រភេទ និងបន្ថែមចំណាត់ថ្នាក់របស់អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្នុងឆ្នាំ២០១៤ មានក្រុមហ៊ុនចូលដេញថ្លៃគម្រោងសាងសង់មួយចំនួនដែលមានទឹកប្រាក់កិច្ចសន្យាលទ្ធកម្មលើសពី ៥០០ លានរៀល ប៉ុន្តែភ្ជាប់នូវវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ប្រភេទតូច និងប្រភេទមធ្យមប៉ុណ្ណោះ។ ការភ្ជាប់នូវវិញ្ញាបនបត្រពុំត្រឹមត្រូវតាមកម្រិតសមត្ថភាព នាំឱ្យការដេញថ្លៃប្រកួតប្រជែងជាសាធារណៈមិនទាន់មានលក្ខណៈសមស្រប និងប្រសិទ្ធភាពការងារ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍។

ជាការឆ្លើយតប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិលើចំណុចស្តីពីក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់វិញ្ញាបនប័ត្រចុះបញ្ជីសាងសង់មិនសមស្រប ព្រោះថាគោលការណ៍ណែនាំលេខ០២ លសា ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកតាមប្រភេទ និងការចុះបញ្ជីរបស់អ្នកទទួលការ ត្រូវបានអនុវត្ត២០ឆ្នាំមកហើយ ហើយដែលត្រូវធ្វើបច្ចុប្បន្នភាពឱ្យសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

### ៣.១.៨. ការប្រើប្រាស់ថវិកាខុសមាតិកាថវិកា

ដើម្បីកត់ត្រាចំណាយថវិការដ្ឋឱ្យបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៥៨៨ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីណែនាំក្រសួង ស្ថាប័នប្រើប្រាស់ថវិកា ក៏ដូចជាការកត់ត្រាតួលេខចំណាយឱ្យបានសមស្របទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចដូចជាជំពូក៦១ (គណនី៦១៥) បានបញ្ជាក់អំពីការកត់ត្រារាល់ការចំណាយលើការថែទាំ និងជួសជុល ដូចជាលើការងារលាបថ្នាំ ការរៀបចំបណ្ដាញឡើងវិញ ដែលបណ្ដាលមកពីការជួសជុលអគារ និងការជួសជុលរបងអគារ...។ រីឯជំពូក២១ (គណនី២១៣) បានបញ្ជាក់អំពីការកត់ត្រារាល់ការចំណាយលើការសាងសង់អគាររដ្ឋបាលសម្រាប់បម្រើការងាររាជរដ្ឋាភិបាល។

តាមការធ្វើសវនកម្មលើរបាយការណ៍សម្រេចទូទាត់ថវិកាទូទៅរបស់ក្រសួងសុខាភិបាលឆ្នាំ២០១៤ និងអាណត្តិបើកប្រាក់ និងឯកសារលទ្ធកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសុខាភិបាលបានធ្វើការសាងសង់អគាររះកាត់ចំនួនមួយ និងរៀបចំបណ្ដាញអុកស៊ីសែន ដោយប្រើប្រាស់ថវិកាចំណាយចរន្តជំពូក៦១ គណនី៦១៥ ដែលមានទឹកប្រាក់ចំនួន ២ ៩០៧ ៦៥២ ៧០០ រៀល *( តួលេខទឹកប្រាក់ក្នុងអណត្តិបើកប្រាក់ចំនួន ៣ ៩៨៧ ៥០០ ០០០រៀល រួមបញ្ចូលទាំងការរៀបចំជញ្ជាំងកញ្ចក់ខណ្ឌការិយាល័យរោងដាក់កង់ម៉ូតូ និងរៀបចំសាលប្រជុំនៅទីស្ដីការក្រសួងសុខាភិបាល)* និងគណនី៦១៥ (ការរៀបចំបណ្ដាញអុកស៊ីសែន) មានទឹកប្រាក់ចំនួន ៣ ៥៥៧ ៨០០ ០០០ រៀល ( *តួលេខទឹកប្រាក់ក្នុងអណត្តិបើកប្រាក់ចំនួន ៥ ២២០ ០០០ ០០០រៀល រួមបញ្ចូលទាំងការជួសជុលកែលម្អអគារ)* ជំនួសឱ្យជំពូក២១ គណនី២១៣ ។

ការប្រើប្រាស់ថវិការដ្ឋ និងការកត់ត្រាចំណាយថវិការដ្ឋមិនត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុ ដែលបង្ហាញក្នុងរបាយការណ៍ចំណាយថវិការបស់រដ្ឋមិនបង្ហាញត្រឹមត្រូវតាមការពិត។ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងសុខាភិបាលប្រើប្រាស់ និងកត់ត្រាតួលេខចំណាយថវិកាឱ្យបានត្រឹមត្រូវតាមមាតិកាថវិកា ដើម្បីផ្ដល់ព័ត៌មានត្រឹមត្រូវដល់អ្នកប្រើប្រាស់របាយការណ៍។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសុខាភិបាលបានបំភ្លឺថា ករណីនេះដោយសារមានតម្រូវការបន្ទាន់ សម្រាប់អភិវឌ្ឍន៍នៅខេត្តត្បូងឃ្មុំ ហើយក្រសួងក៏បានពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានសម្រេចប្រើប្រាស់ថវិកាចរន្តជំនួសថវិកាវិនិយោគ។ ចំណែកឯការរៀបចំបណ្ដាញអុកស៊ីសែននៅអគារអ្នកជម្ងឺគ្រីក្រមន្ទីរពេទ្យកាល់ម៉ែត គឺធ្វើឡើងនៅចុងឆ្នាំ តាមការស្នើសុំពីនាយកមន្ទីរពេទ្យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងនៃចំនួនអ្នកជម្ងឺដែលមកសម្រាកព្យាបាល ហើយក្រសួងក៏ទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែរ។

### ៣.១.៩.ការចំណាយថវិការដ្ឋទេយ្យបុរេប្រទានដោយគ្មានការអនុញ្ញាតពីអាណាប័ក

ដើម្បីធានាឱ្យមានតម្លាភាព និងការទទួលខុសត្រូវក្នុងការចំណាយថវិការដ្ឋនៅតាមក្រសួង និងស្ថាប័ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ដែលជាគោលការណ៍តម្រូវឱ្យរដ្ឋទេយ្យបុរេប្រទានមុននឹងចំណាយត្រូវស្នើសុំគោលការណ៍ទៅអាណាប័ក ឬអ្នកដែលត្រូវបានផ្ទេរសិទ្ធិ ហើយការចំណាយនោះត្រូវមានសក្ខីបត្របញ្ជាក់ត្រឹមត្រូវ។

តាមការធ្វើសវនកម្មលើឯកសារចំណាយថវិកាតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន នៅក្រសួងសុខាភិបាល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រាល់ប្រតិបត្តិការចំណាយតាមរូបភាពរដ្ឋទេយ្យបុរេប្រទានទាំងអស់ ដែលមានទឹកប្រាក់សរុបចំនួន ៥៨២ ៦៩៣ ៦៩១ រៀល មិនមានការអនុញ្ញាតពីអាណាប័ក ឬអ្នកដែលត្រូវបានផ្ទេរសិទ្ធិឡើយ។

ប្រការនេះ នាំឱ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។

អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងសុខាភិបាលអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ដែលបានកំណត់។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសុខាភិបាលបានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងបានរៀបចំធ្វើការកែលម្អ។

### ៣.១.១០.ការមិនបានបែងចែកភារកិច្ចរវាងអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

ការធ្វើសវនកម្មផ្ទៃក្នុងមានបំណងជួយក្រសួង ស្ថាប័នបំពេញការទទួលខុសត្រូវរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ តួនាទីរបស់សវនកម្មផ្ទៃក្នុង គឺត្រូវវាយតម្លៃដោយឯករាជ្យនូវភាពសមស្រប គ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់ការធានាលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យ។ ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវ សវនករផ្ទៃក្នុងត្រូវមានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ និងគ្មានការរារាំង ការហាមឃាត់លើការចូលត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព។ ជាងនេះទៀត ប្រធានក្រសួង ស្ថាប័ននីមួយៗត្រូវសម្របសម្រួលបែងចែកភារកិច្ចរវាងអគ្គាធិការដ្ឋាន ឬអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងនេះឲ្យបានសមស្រប។

តាមការធ្វើសវនកម្មលើរបាយការណ៍សវនកម្ម និងរបាយការណ៍អធិការកិច្ច ព្រមទាំងការសាកសួរទៅអង្គភាពទាំងពីរនេះនៃក្រសួងសុខាភិបាល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋានបំពេញការងារដូចគ្នា និងមិនមានការបែងចែកភារកិច្ចឱ្យដាច់ពីគ្នាឡើយ។ ម្យ៉ាងទៀត នាយកដ្ឋានសវនកម្មផ្ទៃក្នុងមិនត្រូវបានអនុញ្ញាតឱ្យធ្វើសវនកម្មនៅទីស្តីការក្រសួងសុខាភិបាលទេ។

ប្រកានេះ ធ្វើឲ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុងមិនមានឯករាជ្យភាពអំពីកិច្ចប្រតិបត្តិការការងាររបស់ខ្លួនឱ្យបានពេញលេញ។

អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងសុខាភិបាលបែងចែកភារកិច្ចឲ្យបានច្បាស់លាស់រវាងអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ដើម្បីឱ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងាររបស់ខ្លួនបានពេញលេញ និងត្រឹមត្រូវ។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសុខាភិបាលបានបំភ្លឺថា អគ្គាធិការដ្ឋានអនុវត្តតាមអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល។ សវនកម្មផ្ទៃក្នុងអនុវត្តតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

**៣.១.១១.កង្វះខាតការប្រមូលផ្តុំកិច្ចលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម**

ដើម្បីពង្រឹងកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយតម្លាភាព សង្គតិភាព ការប្រកួតប្រជែង ភាពតែមួយនៃការអនុវត្តវិធីសាស្ត្រលទ្ធកម្ម ការធានាឱ្យបាននូវភាពសន្សំសំចៃ និងប្រសិទ្ធភាពក្នុងដំណើរការអនុវត្តវិធីសាស្ត្រលទ្ធកម្មដែលទាក់ទងទៅនឹងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងលទ្ធកម្មទីប្រឹក្សាក្នុងន័យសំដៅដល់ការប្រមូលផ្តុំនូវប្រភេទលទ្ធកម្មដែលមានលក្ខណៈដូចគ្នា ស្រដៀងគ្នា ដើម្បីដាក់ជាឡូត៍លទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានខិតខំចេញនូវសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ត្រង់ចំណុចទីIII បានចែងថា"ត្រូវប្រមូលផ្តុំតម្រូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នាស្រដៀងគ្នា ឬបម្រើការតែមួយបញ្ចូលក្នុងក្រុមតែមួយដែលហៅថាឡូត៍លទ្ធកម្ម ដើម្បីធ្វើកិច្ចលទ្ធកម្មតែមួយលើក។ ឡូត៍លទ្ធកម្មមួយចំនួនដែលមានភាពប្រហាក់ប្រហែល ឬស្រដៀងគ្នាត្រូវបញ្ចូលគ្នាជាក្រុមធំមួយហៅថា កញ្ចប់លទ្ធកម្មសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក "។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡាពុំទាន់ធ្វើការប្រមូលផ្តុំកិច្ចលទ្ធកម្ម ដើម្បីដាក់ជាកញ្ចប់លទ្ធកម្មនូវប្រភេទលទ្ធកម្មដែលស្ថិតនៅក្នុងប្រភេទដូចគ្នា ឬស្រដៀងគ្នា ឬបម្រើការតែមួយ ដើម្បីធ្វើលទ្ធកម្មតែមួយលើក។

ក្រសួងគួរអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងបានបញ្ជាក់ថា កាលដែលក្រសួងមិនបានធ្វើការប្រមូលផ្តុំលទ្ធកម្មដាក់ជាកញ្ចប់លទ្ធកម្ម ដោយសារអង្គភាពលទ្ធកម្មបានរៀបចំឯកសារដេញថ្លៃជាលក្ខណៈអន្តរជាតិតែមួយ ដោយរួមបញ្ចូលលិខិតផ្តល់តណទានធានាចំណាយទាំងពីររួមគ្នាឱ្យស្របតាមផែនការលទ្ធកម្ម ក៏ប៉ុន្តែដោយមានការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) តម្រូវឱ្យអង្គភាពលទ្ធកម្មធ្វើការបំបែកឯកសារជាពីរឱ្យស្របតាមគោលការណ៍តណទានធានាចំណាយដែលបានផ្តល់ជូន បើ

ទោះបីជាបំបែកឯកសារដេញថ្លៃជាពីរ ក៏ក្រសួងអប់រំ យុវជន និងកីឡា មិនបានគេចវេសពីនីតិវិធីលទ្ធកម្មឡើយដោយរក្សាការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិដដែល។ ឯកសារដេញថ្លៃទាំងនោះក៏បានឆ្លងការពិនិត្យ សម្រេច និងយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋានគោលការណ៍ធានាចំណាយពីរផ្សេងគ្នា និងលក្ខខណ្ឌសមត្ថភាព(ហិរញ្ញវត្ថុ បច្ចេកទេស និងបទពិសោធន៍) របស់អ្នកចូលរួមដេញថ្លៃ និងការផ្គត់ផ្គង់សម្ភារៈ និងការជួសជុល កែលម្អសំណង់ ហើយដោយការងារអនុវត្តកិច្ចលទ្ធកម្មមិនទទួលបានជោគជ័យក្នុងការដេញថ្លៃ ដូចនេះក្រសួងអប់រំ យុវជន និងកីឡា មិនអាចទម្លាក់ចោលនូវឥណទានដែលមានស្រាប់នេះ គឺបង្វែរទៅការងារជួសជុលសេសសល់ផ្សេងៗនៅក្នុងពហុកីឡាដ្ឋានជាតិអូឡាំពិកវិញ ដើម្បីឱ្យមានសោភ័ណ្ឌភាពស្របទៅតាមកំណែទម្រង់របស់ប្រមុខរាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យកីឡាកាន់តែមានការរីកចម្រើនឆាប់រហ័ស និងទាក់ទាញយុវជនឱ្យចូលរួម។

### ៣.១.១២.ការពុំទាន់បានកត់ត្រាចំណូលផ្សេងៗ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រង់មាត្រា ១៩ បានចែងថា " ចំណូលត្រូវកត់ត្រាចូលទាំងស្រុង ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៤ គ្រឹះស្ថានសាធារណៈមួយចំនួនបានប្រមូលចំណូលមួយចំនួនដោយពុំទាន់បានកត់ត្រាចូលក្នុងរបាយការណ៍ចំណូល និងចំណាយ ដូចបង្ហាញខាងក្រោម ៖

- ចំណូលពីអាហារដ្ឋាន ចំនួន១ ០០០ ០០០ រៀល
- ចំណូលពីសេវាផ្ញើកង់ ម៉ូតូ ចំនួន២ ០០០ ០០០ រៀល

កត្តានេះ អាចនាំឱ្យរបាយការណ៍ចំណូលមិនឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែង។ គ្រឹះស្ថាន សាធារណៈមួយចំនួន ត្រូវកត់ត្រាគ្រប់ចំណូលទាំងអស់ឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ជាការឆ្លើយតប

គ្រឹះស្ថានសាធារណៈមួយចំនួនបានឯកភាពលើរបាយការណ៍សវនកម្ម ហើយបាន និងកំពុងអនុវត្តឱ្យបានពេញលេញនូវការកត់ត្រាចំណូល និងចំណាយនេះ ដើម្បីឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

### ៣.១.១៣.ការអនុវត្តកិច្ចលទ្ធកម្មពុំមានក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ

សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មចាំបាច់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនរាល់គម្រោងចំណាយដែលត្រូវអនុវត្ត

តាមវិធីសាស្រ្ត នីតិវិធីលទ្ធកម្ម ត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីមិនបានកត់ត្រាក្នុងផែនការលទ្ធកម្មមិនត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចលទ្ធកម្មឡើយ ហើយសាមីស្ថាប័នអនុវត្តលទ្ធកម្មត្រូវទទួលខុសត្រូវរាល់សកម្មភាពអសកម្មដែលនឹងកើតឡើងជាយថាហេតុ"។

តាមការចុះធ្វើសវនកម្មនៅក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការិយបរិច្ឆេទ ២០១៤ ក្រសួងបានលើកផែនការលទ្ធកម្ម និងផែនការលទ្ធកម្មកែតម្រូវឆ្នាំ២០១៤ មានចំនួន២៨គម្រោង ក្នុងនោះមានលទ្ធកម្មទំនិញចំនួន១០ សេវាកម្មចំនួន២ និងលទ្ធកម្មសំណង់ចំនួន១៦គម្រោង ប៉ុន្តែតាមរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៤របស់ក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ឆ្នាំ២០១៤ មានរហូតដល់ ១៨០គម្រោង ដែលលើសពីផែនការលទ្ធកម្មកែតម្រូវចំនួន១៥២គម្រោង ហើយគម្រោងទាំងនេះអនុវត្តកិច្ចលទ្ធកម្មតាមវិធីសាស្រ្តលទ្ធកម្មដោយឡែក។

ករណីនេះ នាំឲ្យការធ្វើកិច្ចលទ្ធកម្មមិនស្របតាមផែនការប្រចាំឆ្នាំ និងការចំណាយថវិកាមានភាពមិនច្បាស់លាស់។

អាស្រ័យហេតុនេះ ក្រសួងអភិវឌ្ឍន៍ជនបទ គួរអនុវត្តកិច្ចលទ្ធកម្មសាធារណៈឲ្យស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ក្រសួងអភិវឌ្ឍន៍ជនបទសូមឯកភាពលើចំណុចរកឃើញខាងលើ ដោយសូមធ្វើការបំភ្លឺថា ក្រោយទទួលបានអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្រសួងបានធ្វើការកែសម្រួល ដោយបានដាក់បញ្ចូលគម្រោងទៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំរួចរាល់ហើយ (គម្រោងសាងសង់អណ្តូង និងបង្គន់) សម្រាប់ការអនុវត្តផែនការឆ្នាំ២០១៥ និងឆ្នាំបន្តបន្ទាប់ទៀត។

### ៣.១.១៤.ភាពយឺតយ៉ាវក្នុងការផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិកា

ប្រកាសណែនាំលេខ ១៣៩៥ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៤ ត្រង់ចំណុចទី២ ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៤ បានបញ្ជាក់ថា " ចំពោះក្រសួងស្ថាប័ន រដ្ឋបាលកណ្តាលត្រូវផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិការបស់ខ្លួនជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានបញ្ចូលចំណូល ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទនៅតាមរាជធានី ខេត្ត រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានចំណូល ចំណាយថវិកា និងអគ្គនាយកដ្ឋានថវិកានីយកម្ម) ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥ជាកំហិត"។

តាមការចុះធ្វើសវនកម្មនៅក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការិយបរិច្ឆេទ ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតថា រហូតមកដល់ខែឧសភា ឆ្នាំ២០១៥ ក្រសួងអភិវឌ្ឍន៍ជនបទ នៅពុំទាន់បានបញ្ចប់ការផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិកាជាមួយនឹងអគ្គនាយកដ្ឋានរតនាគារជាតិនៅឡើយ។

ករណីនេះ អាចនាំឲ្យការគ្រោងថវិកាឆ្នាំបន្ទាប់មានភាពមិនច្បាស់លាស់។ ក្រសួងអភិវឌ្ឍន៍ជនបទគួរអនុវត្តការងារឲ្យស្របតាមប្រកាសណែនាំខាងលើនេះ។

ជាការឆ្លើយតប ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលស្គាល់ថាពិតជាមានភាពយឺតយ៉ាវបន្តិចមែន ប៉ុន្តែសូមធ្វើការបំភ្លឺថា ជាទូទៅក្រសួងអភិវឌ្ឍន៍ជនបទតែងតែខិតខំធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូលចំណាយថវិកា ដើម្បីផ្ទៀងផ្ទាត់តួលេខជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ និងផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានទាន់ពេលវេលា ប៉ុន្តែដោយឡែកឆ្នាំ២០១៤នេះ ក្រសួងមានការយឺតយ៉ាវក្នុងការប្រមូលឯកសារផ្ទៀងផ្ទាត់ដោយសារមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្តមួយចំនួនមានភាពយឺតយ៉ាវក្នុងការផ្ទៀងផ្ទាត់តួលេខជាមួយរតនាគារខេត្តទើបធ្វើឲ្យក្រសួងត្រូវរង់ចាំ និងមានភាពយឺតយ៉ាវបែបនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រសួងបានធ្វើការផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិកាឆ្នាំ ២០១៤ ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិរួចរាល់ហើយ។

## ៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត -ក្រុង និងខណ្ឌ-ស្រុក ត្រង់ឧបសម្ព័ន្ធ២ ជំពូក២១ គណនី២១៣ បានអនុញ្ញាតឲ្យខេត្ត ក៏ដូចជាបណ្តាមន្ទីរជុំវិញ អនុវត្តមាតិកាចំណាយថវិការបស់ខ្លួនឱ្យបានសមស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនោះ អនុគណនី២១៣១ ស្តីពីសំណង់អគារ អនុគណនី២១៣២ ស្តីពីការរៀបចំកែលម្អអគារ និងអនុគណនី ២១៣៨ ស្តីពីសំណង់ផ្សេងៗទៀត។ រីឯជំពូក៦១ (៦១៥២) កត់ត្រាការចំណាយលើការថែទាំ ជួសជុលអគារ និងប្រាសាទ។ តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មនៅខេត្តចំនួន ០៦ គឺខេត្តកែប កំពត ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី ឃើញថា អាណាបក្សប្រទានសិទ្ធិ និងអភិបាលហិរញ្ញវត្ថុខេត្តបានអនុញ្ញាតឱ្យសាលាខេត្ត និងមន្ទីរជុំវិញខេត្តមួយចំនួនយកថវិកាជំពូក៦១ គណនី ៦១៥ អនុគណនី៦១៥២ មកចំណាយលើការងារសាងសង់អគារ របង ស្ពាន ផ្លូវ ខុសពីគោលការណ៍បានកំណត់។

ដោយសារការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា បានធ្វើឱ្យប៉ះពាល់ដល់គោលនយោបាយហិរញ្ញវត្ថុ និងតួលេខនៃគណនីចំណាយក្នុងរបាយការណ៍ទូទាត់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ របស់សាលាខេត្ត និងមន្ទីរមួយចំនួន

ផ្លុះបញ្ចាំងមិនពិតប្រាកដ។ ដោយហេតុនេះ សាលាខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពអនុវត្តគម្រោងគួរអនុវត្តតាមប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនបានឯកភាព និងមួយចំនួនទៀតថា អនុវត្តតាមផែនការអភិវឌ្ឍន៍ និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំលើការជួសជុលកែលម្អផ្លូវដែលមានស្រាប់។

### ៣.២.២.ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់

ប្រកាសលេខ ៣៨១ ប្រក.សហវ/២០១០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី ២ ចំណុច ៣.១៤.៨ បានបញ្ជាក់ថា ជាទូទៅ ការត្រួតពិនិត្យកិច្ចសន្យាសំណង់មានការស្មុគស្មាញ ដោយសារកត្តាទាំងឡាយដែលមិនអាចដឹងបានមុនពេលចាប់ផ្តើមការងារ។ ដូច្នេះ តម្រូវឱ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីធ្វើការគ្រប់គ្រងទីតាំងគម្រោង និងត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់ "អ្នកទទួលការ"។ អ្នកគ្រប់គ្រងគម្រោងអាចជាបុគ្គលនៅក្នុងអង្គភាពលទ្ធកម្ម ឬជាទីប្រឹក្សាជំនាញ ឬជាបុគ្គលដែលមានជំនាញមកពីស្ថាប័នអនុវត្តលទ្ធកម្ម។ អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាដែលកើតមានឡើងក្នុងពេលអនុវត្តការងារ។ តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មនៅខេត្តចំនួន០៤ គឺខេត្តកែប រតនគិរី ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី ឃើញថា ការសាងសង់សំណង់អគារ ផ្លូវ.. គឺមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសាងសង់របស់អ្នកទទួលការ និងធ្វើរបាយការណ៍វឌ្ឍនភាពឡើយ។

ដោយសារការពុំបានចាត់តាំងឱ្យមានអ្នកគ្រប់គ្រងគម្រោង ទើបគ្មានរបាយការណ៍វឌ្ឍនភាព ដែលនេះជាហេតុនាំឱ្យការវាយតម្លៃរបស់គណៈកម្មការប្រគល់ទទួលសំណង់ពុំមានមូលដ្ឋានច្បាស់លាស់ ហើយសំណង់អាចខុសប្លង់បច្ចេកទេស និងមានគុណភាពមិនសូវល្អ។

អាស្រ័យហេតុនេះ សាលាខេត្តគួរណែនាំអង្គភាពលទ្ធកម្ម និងអង្គភាពអនុវត្តលទ្ធកម្មឱ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានរាល់ការងាររបស់អ្នកទទួលការ និងរាល់បញ្ហាដែលកើតមានក្នុងអំឡុងពេលអនុវត្តការងារ ព្រមទាំងរាយការណ៍ និងធ្វើរបាយការណ៍វឌ្ឍនភាពជូនថ្នាក់ដឹកនាំជាប្រចាំ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តបានឯកភាពថា មិនបានចាត់តាំងជាលាយលក្ខណ៍អក្សរមែន តែបានប្រគល់ការងារតាមដានត្រួតពិនិត្យនេះទៅម្ចាស់គម្រោងតាមដានដោយផ្ទាល់។

### ៣.២.៣.ការមិនបានកត់ត្រាទ្រព្យសម្បត្តិរដ្ឋចូលក្នុងបញ្ជីសារពើភណ្ឌ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ ០០១ សហវ. ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៣ ស្តីពីការកែសម្រួលធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយណែនាំថា បញ្ជីសារពើភណ្ឌរបស់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង មន្ទីរជំនាញ និងស្រុក-ខណ្ឌនានា ដែលបានធ្វើបញ្ជីសារពើភណ្ឌរួចរាល់ហើយ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាប្រចាំ ដោយយកបញ្ជីសារពើភណ្ឌឆ្នាំកន្លងទៅនេះធ្វើជាមូលដ្ឋាន និងត្រូវមានកំណត់ហេតុផ្ទៀងផ្ទាត់។ ក្នុងកំណត់ហេតុនេះ ត្រូវបញ្ជាក់អំពីទ្រព្យសម្បត្តិកើនឡើង ឬថយចុះតាមឆ្នាំ និងមានមូលហេតុឱបានច្បាស់លាស់នៃការកើនឡើង និងថយចុះនេះ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាលាខេត្តមួយចំនួនមិនបានកត់ត្រាបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីសារពើភណ្ឌ ដែលនាំឱ្យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលបានរៀបចំរួចនោះឆ្លុះបញ្ចាំងមិនត្រឹមត្រូវ និងនាំឱ្យទ្រព្យសម្បត្តិដែលនៅក្រៅបញ្ជីអាចបាត់បង់ជាយថាហេតុ។ ដូចនេះ សាលាខេត្តគួរជំរុញអង្គភាពកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ខេត្តឱ្យកត់ត្រាបញ្ចូលទ្រព្យសម្បត្តិដែលនៅសេសសល់ក្រៅបញ្ជីទាំងនោះទៅក្នុងបញ្ជីសារពើភណ្ឌសម្បត្តិរដ្ឋរបស់អង្គភាពឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តខ្លះបានបំភ្លឺថា សាលាខេត្តបានបញ្ចូលទ្រព្យសម្បត្តិរដ្ឋទៅក្នុងបញ្ជីរួចរាល់ហើយ និងសាលាខេត្តខ្លះទៀតថា នឹងជំរុញគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់សាលាខេត្តឱ្យកត់ត្រាទ្រព្យសម្បត្តិទាំងនោះចូលក្នុងបញ្ជីសារពើភណ្ឌសម្បត្តិរដ្ឋនាពេលខាងមុខ។

### ៣.២.៤. ការប្រមូលចំណូលពីការអនុញ្ញាតរដ្ឋបាលនៅមានកម្រិត

សារាចរណែនាំលេខ០០៤ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការអនុវត្តថវិការាជធានី ខេត្ត ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់ចំណុច ក.២ បានចែងថា ចំពោះចំណូលមិនមែនសារពើពន្ធដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលសម្រាប់ថវិការាជធានី ខេត្ត រាជធានី ខេត្តត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូលដែលត្រូវប្រមូលបង់ចូលរតនាគារឱ្យអស់ មិនត្រូវទុកចំណូលខ្លះនៅដោយឡែក សម្រាប់ចំណាយដោយឡែកក្រៅពីគម្រោងចំណាយប្រចាំឆ្នាំឡើយ។ ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលរាជធានី ខេត្តបានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិការាជធានី ខេត្តដែរ ជៀសវាងទុកចំណូលនោះដោយឡែកសម្រាប់ចំណាយដោយឡែកគ្មានតម្លាភាព”។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៤ សាលាខេត្តព្រៃវែងអនុវត្តការប្រមូលចំណូលលើការអនុញ្ញាតរដ្ឋបាល បានតែមួយមុខសញ្ញាតែប៉ុណ្ណោះក្នុងចំណោមមុខសញ្ញាទាំងអស់ចំនួន៦ ដែលមានទឹកប្រាក់សរុបចំនួន ២ ៣៨០ ០០០រៀល។

ករណីនេះ នាំឱ្យបាត់បង់ចំណូលថវិកាខេត្ត។

អាស្រ័យហេតុនេះ សាលាខេត្ត គួរជំរុញឱ្យអង្គភាពក្រោមឱវាទ ធ្វើការប្រមូលចំណូលគ្រប់ប្រភេទ គ្រប់មុខសញ្ញាដែលស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

សាលាខេត្តបានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដោយឡែកការងាររបស់អនុគណៈកម្មការវិនិយោគខេត្តមិនអាចដំណើរការបានឡើយ ព្រោះថាមិនមានក្រុមហ៊ុនណាមួយមកធ្វើការទំនាក់ទំនងចុះបញ្ជី ដើម្បីធ្វើការវិនិយោគអ្វីឡើយក្នុងភូមិសាស្ត្រខេត្ត។

## ៤. ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៤ និងនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួនដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឲ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

**៤.១. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ:** ច្បាប់ស្តីពីសារពើពន្ធ បានកំណត់ឲ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជី លិខិត យុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការធ្វើសវនកម្មសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន១៩១ ក្រុមហ៊ុនសហគ្រាស ក្នុងការិយបរិច្ឆេទ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៨៩ក្រុមហ៊ុន សហគ្រាស (ក្រុមហ៊ុន សហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន០៩ និងស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមចំនួន៨០) មិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ ករណីនេះ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាព ដើម្បីកែលម្អ និងជំរុញឱ្យអ្នកជាប់ពន្ធកាន់កាប់បញ្ជីស្មាមឱ្យបានត្រឹមត្រូវ ដោយបាននិងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាច្រើនដល់អ្នកជាប់ពន្ធនានា តាមវិស័យអាជីវកម្មសំខាន់ៗ ដើម្បីពន្យល់ណែនាំពីការកាន់បញ្ជីកាគណនេយ្យឲ្យបានត្រឹមត្រូវ បានធ្វើការណែនាំដល់មន្ត្រីចាត់ចែងលិខិតប្រកាស និងសវនករគ្រប់រូបឲ្យយកចិត្តទុកដាក់ចំពោះការកាន់បញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធនៅពេលប្រកាស និងពេលចុះធ្វើសវនកម្ម និងបាននិងកំពុងរៀបចំ និងបោះពុម្ពសៀវភៅណែនាំស្តីពីការកាន់កាប់ កត់ត្រាបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសជាអ្នកជាប់ពន្ធតូច។

**៤.២. ការបំពេញកាតព្វកិច្ចសារពើពន្ធ:** ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។ តាមការធ្វើសវនកម្មលើបញ្ជីឈ្មោះក្រុមហ៊ុនសហគ្រាសដែលបានចុះបញ្ជី និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះ លោក លោកស្រីនាយកក្រុមហ៊ុន សហគ្រាសនីមួយៗឲ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែប្រចាំឆ្នាំ នៅអង្គភាពពន្ធ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៤ មានក្រុមហ៊ុនមួយចំនួនមិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១៤ទេ។ ករណីក្រុមហ៊ុនមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធៈនេះ អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងរៀបចំក្រុមការងារ ដើម្បីចុះអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារ បានគ្រប់ៗគ្នា។ ទន្ទឹមគ្នានេះដែរ អគ្គនាយកដ្ឋានពន្ធដារបាន និងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវប្បធម៌នៃការបង់ពន្ធតាមរយៈកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងតាមរយៈគោលនយោបាយបញ្ច្រាបវប្បធម៌បង់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដែលតម្រូវឲ្យនាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត-ខណ្ឌ រៀបចំសិក្ខាសាលាតាមវិស័យអាជីវកម្មជូនអ្នកជាប់ពន្ធ។

**៤.៣. របាយការណ៍សវនកម្មរបស់សវនកររងករាជ្យ:** សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនកររងករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១)ផលរបរប្រចាំឆ្នាំសហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣)និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនកររងករាជ្យ។ ក្នុងឆ្នាំ២០១៤ នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ បានចុះធ្វើសវនកម្មលើសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យ ដែលត្រូវមានរបាយការណ៍សវនកម្មរបស់សវនកររងករាជ្យចំនួន១៤០។ ក្នុងនោះមានសហគ្រាសចំនួន១៦ ពុំមានរបាយការណ៍សវនកម្មរបស់សវនកររងករាជ្យឡើយ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងរៀបចំសៀវភៅណែនាំស្តីពីការធ្វើសវនកម្មសហគ្រាស និងកំពុងជំរុញឲ្យអ្នកជាប់ពន្ធតាមវិស័យមួយចំនួនដែលស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺតម្រូវឲ្យមានរបាយការណ៍ហិរញ្ញវត្ថុពីស្នងការគណនេយ្យឯករាជ្យ។

**៤.៤. ការប្រើប្រាស់វិក្កយបត្រ:** តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឲ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឲ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេសដូចជាៈ ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬ

ភ្ជាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ ប៉ុន្តែ អាជីវកម្មរបបស្វ័យប្រកាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់ត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជាវិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ..។ ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានច្បាស់លាស់ អាចពុំបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ និងការធ្វើសវនកម្ម។ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំផែនការសកម្មភាពសម្រាប់កែលម្អករណីនេះ ដោយបានណែនាំផ្សព្វផ្សាយអំពីការប្រើប្រាស់វិក្កយបត្រឱ្យបានសមស្របតាមបទប្បញ្ញត្តិ ដោយបានចេញសេចក្តីណែនាំថ្មីលេខ ១១២៧ អពដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស ដោយបានបោះពុម្ពការប្រើប្រាស់វិក្កយបត្រចែកជូនម្ចាស់សហគ្រាសទាំងអស់ និងកំពុងពង្រឹងយន្តការនៃការប្រើប្រាស់វិក្កយបត្រនេះដល់មន្ត្រីទាំងអស់ និងបានធ្វើសវនកម្មដោយមានទាំងការពិន័យទោសទណ្ឌចំពោះក្រុមហ៊ុន សហគ្រាសមួយចំនួនដែលប្រើប្រាស់វិក្កយបត្រមិនបានត្រឹមត្រូវ។

**៤.៥. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ:** ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើសវនកម្មអាជ្ញាធរសវនកម្មសង្កេតឃើញថា ក្រុមហ៊ុន សហគ្រាសមួយចំនួនបានប្រកាសពន្ធមិនត្រឹមត្រូវ និងសមស្រប ដូចជា៖ មិនបានភ្ជាប់ទិន្នានុប្បវត្តិលក់ ទិញ មិនបានបំពេញលើលិខិតប្រកាសគ្រប់ខ្ទង់ គ្រប់និទ្ទេស ផលដែលបានប្រកាសនៅទាប ផលប្រកាសប្រចាំខែ និងប្រចាំឆ្នាំខុសគ្នា។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញផែនការសកម្មភាពសម្រាប់កែលម្អ ដើម្បីពង្រឹងការត្រួតពិនិត្យលើលិខិតប្រកាសពន្ធដោយមានមន្ត្រីទទួលបន្ទុកពិនិត្យ និងណែនាំចំពោះក្រុមហ៊ុនសហគ្រាសដែលដាក់លិខិតប្រកាសមិនត្រឹមត្រូវ មិនគ្រប់ខ្ទង់ និងមិនគ្រប់និទ្ទេស ថែមទាំងជំរុញការធ្វើសវនកម្មលើលិខិតស្នាមដោយកំណត់ពន្ធឡើងវិញ ចំពោះក្រុមហ៊ុន សហគ្រាសដែលប្រកាសមិនប្រក្រតី និងកំពុងជំរុញការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីចាត់ចែងលិខិតប្រកាស។

**៤.៦. ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស:** ច្បាប់ស្តីពីសារពើពន្ធសហគ្រាសកំណត់ថា ក្រោយពីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចហើយ សហគ្រាសត្រូវរួសរាន់ទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ។ ក្នុងករណីមិនបានទៅចុះបញ្ជីទេនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីចាប់តាំងពីពេលដែលសហគ្រាសត្រូវទៅចុះបញ្ជី ហើយការចុះបញ្ជីបែបនេះសហគ្រាសត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ចាប់តាំងពីកាលបរិច្ឆេទដែលបានកំណត់។ ប៉ុន្តែ តាមការធ្វើសវនកម្មលើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសេវា

អ្នកជាប់ពន្ធ និងបំណុលពន្ធប្រចាំឆ្នាំ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាស (ត្រីមាសទី១ ឆ្នាំ២០១៤) ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មចំនួន ១ ១៨៥ ហើយបានផ្ញើមកអង្គភាពពន្ធក្នុងឆ្នាំ២០១៤។ ក្នុងនោះមានក្រុមហ៊ុន សហគ្រាសចំនួន ៨៣៤ បានមកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ដោយឡែកនៅសល់ក្រុមហ៊ុន សហគ្រាសមួយចំនួនទៀត មិនមកបំពេញកាតព្វកិច្ចពន្ធឱ្យបានសមស្របតាមបទប្បញ្ញត្តិខាងលើទេ។ សហគ្រាសនៅសល់ដែលមិនបានចុះបញ្ជីពន្ធ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាព ដើម្បីកែលម្អ និងការអនុវត្តផែនការសកម្មភាពកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារលើការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពសហគ្រាសដោយបានចេញនូវលិខិតជូនដំណឹង សេចក្តីណែនាំអំពីកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងមានក្រុមការងារធ្វើការផ្ទៀងផ្ទាត់ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅពន្ធដារ និងបានចុះស្វែងរកដោយផ្ទាល់ ព្រមទាំងចែកលិខិតជូនដំណឹងដើម្បីមកចុះបញ្ជីពន្ធដារ និងថតរូបដើម្បីបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ និងការអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារបានគ្រប់ៗគ្នា និងតម្រូវឲ្យសហគ្រាសទាំងអស់មកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឲ្យបានគ្រប់ៗគ្នា។

**៤.៧. ការប្រមូលពន្ធអចលនទ្រព្យ:** គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឲ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ ការអនុវត្តប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិតនៅឡើយ ដោយសារអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនទៀតបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងការយកចិត្តទុកដាក់ប្រមូលពន្ធអចលនទ្រព្យ តាមរយៈយន្តការឃាត់ទុក មិនអនុញ្ញាតឲ្យបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមិនអនុញ្ញាតឲ្យចុះបញ្ជីពន្ធដារ ក្នុងករណីកម្មសិទ្ធិករមិនទាន់បានបង់ពន្ធអចលនទ្រព្យ។

**៤.៨.ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ:** នាយកដ្ឋានរបបគយនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានតួនាទីភារកិច្ចធ្វើការតាមដានសម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះពន្ធនានាតាមទិសដៅ ដែលបានកំណត់ និងត្រួតពិនិត្យលើការប្រើប្រាស់ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋានឬពាណិជ្ជកម្មនានាស្របតាមនីតិវិធីច្បាប់ជាធរមាន។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ពុំមានឯកសារ ឬរបាយការណ៍ ឬកំណត់ហេតុដែលអាចបញ្ជាក់ថា នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យតាមដានលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើមទាំងឡាយដែលបាននាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋនោះឡើយ ដោយពង្រឹងប្រសិទ្ធភាពការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញវិញ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបំភ្លឺថា ការងារនេះបានយកចិត្តទុកដាក់រៀបចំយន្តការ ដើម្បីធ្វើការតាមដាន និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងដោយប្រមូលចំណូលបានជាច្រើន ពីយន្តការ Post Clearance Audit ហើយជាក់ស្តែងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើកិច្ចការជាច្រើន ដូចខាងក្រោម៖

-យោងមាត្រា១៦.៤នៃអនុក្រឹត្យលេខ១១១ អនក្រ. បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (នាយកដ្ឋានរបបគយ)ជាសមាជិក បានចូលរួមក្នុងយន្តការអន្តរស្ថាប័ននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះពិនិត្យការអនុវត្តគម្រោង ការផ្ទេរ ការលក់ ការប្រើប្រាស់នូវសម្ភារ បរិក្ខារ ផលិតកម្ម និងធាតុចូលផលិតកម្មដែលទទួលបានការលើកលែងពន្ធ និងអាករតាមរយៈការស្នើសុំរបស់ក្រុមហ៊ុនវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

-បាននិងកំពុងបន្តចូលរួមអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយលើបណ្តាក្រុមហ៊ុនវិនិយោគ ជាមួយអង្គភាពសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។

-បាននិងកំពុងចូលរួមសហការជាមួយក្រុមការងារ ASYCUDA និងបណ្តាសាខា ការិយាល័យគយ និងរដ្ឋាករពាក់ព័ន្ធតាមដានត្រួតពិនិត្យអនុលោមភាពនៃការនាំចូលទំនិញ តាមរបបប្រវេសន៍កាលិក។

-បានរៀបចំលិខិតលេខ ១៥១០អគរ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ និងបានដាក់ស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីករណីយានយន្តដែលត្រូវបាននាំចូល ដោយលើកលែងពន្ធ និងអាករត្រូវបានលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេង ឬបោះបង់ចោល ដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ។

-បានចូលរួមជាមួយក្រសួងពាណិជ្ជកម្ម ក្នុងគណៈកម្មការត្រួតពិនិត្យបច្ចេកទេស រោងចក្រកាត់ដេរ តាមការស្នើសុំពីក្រសួងពាណិជ្ជកម្ម ក្នុងការពិនិត្យលើសំណើនាំចូលផ្ទាំងក្រណាត់របស់បណ្តាក្រុមហ៊ុនវិនិយោគ។

**៤.៩.ការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចៈ** ការកំណត់ថ្លៃសម្បទានដី និងបង់ប្រាក់កក់ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់(ទាំងចាស់ និងទាំងថ្មី) បានបញ្ជាក់ថា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ត្រូវបង់ថ្លៃឈ្នួលសម្បទានដីប្រចាំឆ្នាំគិតចាប់ពីឆ្នាំទី៦ទៅ តម្លៃចំនួន៥ដុល្លារអាមេរិកក្នុងមួយហិកតា និងកែសម្រួលការតំឡើងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចពី៥%ក្នុងមួយឆ្នាំមកនៅត្រឹម១%ក្នុងមួយឆ្នាំវិញ គិតចាប់ពីឆ្នាំទី៧តទៅ ដោយមិនធ្វើការបែងចែកទៅតាមប្រភេទដំណាំនោះទេ គឺសំដៅដល់សម្បទានដីសេដ្ឋកិច្ច ដែលធ្វើអាជីវកម្មដាំដុះដំណាំកសិកម្មគ្រប់ប្រភេទ។ សារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានបញ្ជាក់ថា អគ្គនាយកដ្ឋាននានាពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅមានការយឺតយ៉ាវក្នុងការ

ប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចដែលហួសរយៈពេលលើកលែងចំនួន៦ឆ្នាំ លើក្រុមហ៊ុនចំនួន ៣៣ស្មើនឹងផ្ទៃដីអាជីវកម្មចំនួន ២៨១ ៥៨១ហិតតា នៃផ្ទៃដីដែលបានចុះកិច្ចសន្យាចំនួន៣៨៩ ១៩៩ ហិតតា ។

**៤.១០.ការខកខានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ក្រសួងស្ថាប័នមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:** អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ សារាចរណែនាំស្តីពីការ រៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ ត្រង់II. កាតព្វកិច្ចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ចែងថា ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវផ្ញើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តគ្រប់កិច្ចលទ្ធកម្មដោយ ភ្ជាប់មកជាមួយនូវទិន្នន័យនៃកិច្ចសន្យា និងឯកសារពាក់ព័ន្ធ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ ឱ្យបានទៀងទាត់រៀងរាល់ខែ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៤ មានក្រសួង ស្ថាប័ន រាជធានី ខេត្ត និង សហគ្រាសសាធារណៈសរុបចំនួន៣០ នៅមិនទាន់បានផ្ញើរបាយការណ៍អំពីការអនុវត្តកិច្ចលទ្ធកម្ម ប្រចាំខែ និងប្រចាំឆ្នាំ មកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៅឡើយ។

**៤.១១. ការកត់ត្រាចំណូលថវិការដ្ឋ:** បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង ស្ថាប័ន រាជធានី ខេត្តដែលបានរៀបចំបញ្ជូនទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបាន កត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កឡើយ ដោយសារ ក្រសួង ស្ថាប័នមួយចំនួនតូច មិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។ ករណីទាំងនេះពាក់ព័ន្ធនឹងប្រភេទចំណូលមួយចំនួនដែលបានកើតមាននៅពេលកៀកចុងឆ្នាំ ហើយជាប្រភេទចំណូលដែលគ្រាន់តែធ្វើនិយ័តកម្មតួលេខ ដូចជា៖ ចំណូលពីកម្រៃរតនាគារ ចំណូលពីវិសមភាពបេឡា និងខ្ទង់ចំណូលមួយចំនួនទៀតនៅកៀកចុងឆ្នាំ និងចំណូលពីឈ្នួល ទីតាំងដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនប្រកាសឥណទានមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ហើយ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋាន រតនាគារជាតិ ហើយដែលរតនាគារជាតិត្រូវបង្ខំចិត្តធ្វើការកត់ត្រាឲ្យបានទាន់ពេលវេលានៅពេល បិទបញ្ជីចុងឆ្នាំ។ បញ្ហានេះប្រសិនបើអគ្គនាយកដ្ឋានរតនាគារជាតិមិនបានកត់ត្រាជាចំណូលទេនោះ នឹងនាំឲ្យមានការបាត់បង់ចំណូលថវិកាជាតិ ព្រោះថាសាច់ប្រាក់បានបង់ចូលបេឡារបស់រដ្ឋរួច ហើយ។

**៤.១២. ការទូទាត់ និងការកត់ត្រាចំណាយ:** ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់ទៅ អគ្គនាយកដ្ឋានរតនាគារជាតិនៅតែមានភាពយឺតយ៉ាវ និងមិនទាន់សមស្រប ដូចជាអាណត្តិបើក ប្រាក់មួយចំនួនដែលបានបោះផ្សាយរួចហើយ ពុំទាន់បានធ្វើការទូទាត់ និងកត់ត្រាចំណាយទាន់

ពេលវេលា អាណត្តិបើកប្រាក់មួយចំនួន តែងតែបានបញ្ជូនទៅរតនាគារជាតិធ្វើការទូទាត់នៅក្រោយថ្ងៃឱសានវាទបិទបញ្ជី ដែលបង្កឲ្យមានការកកស្ទះអាណត្តិបើកប្រាក់ និងលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ជាទូទៅ អាណត្តិដែលបានបញ្ជូនចេញពីអគ្គនាយកដ្ឋានថវិកា ក៏ដូចជាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទៅតាមកាលបរិច្ឆេទកំណត់ (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទ)។ ប៉ុន្តែនៅមានអាណត្តិមួយចំនួនតូចដែលត្រូវការទូទាត់ចំណាយជាចាំបាច់ភ្ជាប់ជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ ដោយប្រើប្រាស់ឥណទានដែលនៅសល់ក្នុងឆ្នាំ។

**៤.១៣.ការមិនបានបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ និងសេវាជួសជុល:** ជាគោលការណ៍ អ្នកដេញថ្លៃបានត្រូវបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់សេវា ឬទំនិញដល់អង្គការសាធារណៈ ប៉ុន្តែតាមការពិនិត្យលើកិច្ចសន្យាស្តីពីការផ្គត់ផ្គង់សម្ភារៈ ទំនិញ និងសេវាជួសជុលផ្សេងៗក្នុងឆ្នាំ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ហើយបានចុះកិច្ចសន្យាមួយចំនួនពុំមានការបង់ពន្ធប្រថាប់ត្រា។

**៤.១៤.ការពុំទាន់បានធ្វើប្លង់កម្មសិទ្ធិដី-អគារ:** លិខិតលេខ៥៣០១ សហវ.ទរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសំណើសុំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បណ្តាក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ត្រូវបានឱ្យក្រសួង-ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ព្រមទាំងបណ្តាមន្ទីរ និងសាលារាជធានី-ខេត្ត ទាំងអស់ត្រូវរៀបចំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋទាំងនោះឱ្យបានឆាប់បំផុត ដោយរួមសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត។ តាមការពិនិត្យលើបញ្ជីសារពើភណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ដីអគារចំនួន០៣ទីតាំងនៅពុំទាន់បានធ្វើប្លង់កម្មសិទ្ធិ ក្នុងនោះរួមមាន ដីបូរីទារក និងកុមារជាតិ (៦ ៧១១ម៉ែត្រការ៉េ) ដីវិទ្យាស្ថានជាតិសង្គមកិច្ច (២ ២៨២ម៉ែត្រការ៉េ) និងដីមជ្ឈមណ្ឌលជាតិព្យាបាល និងនីតិសម្បទា(២០០ ០០០ម៉ែត្រការ៉េ)។

**៤.១៥.ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ:** សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបានតម្រូវឲ្យគ្រប់ក្រសួងស្ថាប័ន និងសាលារាជធានីខេត្តធ្វើបញ្ជីសារពើភណ្ឌលម្អិតសម្រាប់ឆ្នាំ២០០៤ឲ្យបានជាដាច់ខាត ដើម្បីទុកជាឆ្នាំគោលសម្រាប់ការប្រៀបធៀបបញ្ជីសារពើភណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំចន្លោះ០៥ ឆ្នាំស្តីពីការកើនឡើងនិងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឲ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

**៤.១៦. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញលិខិត និងសារាចរណែនាំផ្សេងៗណែនាំឲ្យក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាននិងសាលារាជធានី ខេត្ត ដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យ ដែលបាននិងកំពុងស្ថិតនៅការគ្រប់គ្រងរបស់ខ្លួនឲ្យបានគ្រប់ចំនួន និងឆាប់រហ័សជាប្រយោជន៍ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៤ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

## ៥. សេចក្ដីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានបង្ហាញឲ្យឃើញថារាជរដ្ឋាភិបាលកម្ពុជា ធ្វើឲ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច **៧,១%** លើសពីការព្យាករណ៍ដែលបានរំពឹងទុកក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ មានតែ **៧%** ប៉ុណ្ណោះ ព្រមទាំងសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអាត្រាជាង**១%**ក្នុងមួយឆ្នាំ ដែលធ្វើឲ្យគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលសម្រេចបានមុនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

តាមរយៈការផ្ដល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានា បានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា៖ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។